# សារៈសំខាន់នៃព័ត៌មាន!

## មធ្យោបាយដែលជនមានពិការភាព ទទួលបានព័ត៌មាននៅក្នុងប្រទេសកម្ពុជា



អង្គការឡៃហ្វ៍រឌីវើល និងអង្គការសេវាកម្មអភិវឌ្ឍជនពិការ ២០២០

# សារៈសំខាន់
# នៃព័ត៌មាន!

LIGHT
FOR THE WORLD

អង្គការ សេវាកម្មអភិវឌ្ឍន៍ជនពិការ
DDSP
អសអព
DISABILITY DEVELOPMENT SERVICES PROGRAM

# មាតិកា


សេចក្តីផ្តើម ៦

ហេតុអ្វីបានជាមានការសិក្សានេះ ហើយតើវាកើតឡើងដោយរបៀបណា ? ៧

មធ្យោបាយដែលជនមានពិការភាពតែងប្រើប្រាស់ដើម្បីទទួលបានព័ត៌មាន ១០

ហេតុអ្វីបានជាប្រភពព័ត៌មានមួយចំនួនមានសារៈសំខាន់ ? ១៣

ការទទួលបានព័ត៌មានដែលផ្តល់ឲ្យដោយរដ្ឋាភិបាល ១៥

ការចូលរួមក្នុងព្រឹត្តិការណ៍សហគមន៍នានា ១៧

ការចូលរួមប្រជុំនានា ១៩

លទ្ធភាពទទួលបាន និងភាពជាម្ចាស់លើឯកសារផ្លូវការ ២១

បញ្ហាប្រឈមក្នុងការទទួលបានសេវាសាធារណៈ ២៥

ការស្នើទៅកាន់អាជ្ញាធរ ២៦

សេចក្តីសន្និដ្ឋាន ២៨

# សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ប្រជាជនអាចទទួលបានព័ត៌មានពីសកម្មភាព និងព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងសហគមន៍ ព្រមទាំងអាចផ្តល់ជាមតិយោបល់តាមវិធីផ្សេងៗគ្នា។ នៅឆ្នាំ ២០០៨ យើងបានបោះពុម្ពផ្សាយការសិក្សាមួយដែលមានចំណងជើងថា "សារៈសំខាន់នៃទំនាក់ទំនង"។ លទ្ធផលនៃការសិក្សានេះបង្ហាញថា ជនមានពិការភាពភាគច្រើនមិនអាចមានលទ្ធភាពចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន ហើយក៏ពុំសូវទទួលបានដំណឹងដែលគាត់ត្រូវការដែរ។

យើងចង់សិក្សាឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ថាតើជនមានពិការភាពអាចទទួលបានព័ត៌មានដោយរបៀបណា? តើមធ្យោបាយណាខ្លះដែលធ្វើឲ្យពួកគាត់អាចទទួលបាន និងមិនអាចទទួលបានព័ត៌មាន? ព័ត៌មានទាំងនោះមានសារៈសំខាន់ណាស់សម្រាប់ធ្វើឲ្យយើងស្គាល់ពួកគាត់ឲ្យកាន់តែច្បាស់។ វាមានសារៈសំខាន់ណាស់ ព្រោះជនមានពិការភាពក៏មានសិទ្ធិក្នុងការទទួលបានព័ត៌មាន ហើយពួកគាត់អាចចូលរួមសកម្មភាពសង្គមបានកាន់តែច្រើនផងដែរ ប្រសិនបើពួកគាត់អាចទទួលបានព័ត៌មានដែលគាត់ត្រូវការ។

# ហេតុអ្វីបានជាមានការសិក្សានេះកើតឡើង ហើយតើវាកើតឡើងដោយរបៀបណា?

ការសិក្សានេះកើតឡើងដោយសារយើងចង់ស្វែងយល់ពីមធ្យោបាយនានាដែលជនមានពិការភាពប្រើប្រាស់ដើម្បីទទួលបានព័ត៌មានដើម្បីឲ្យពួកគាត់បានចូលរួមក្នុងសហគមន៍របស់ពួកគាត់។ ការសិក្សានេះធ្វើឡើងនៅខេត្តពោធិ៍សាត់នៅចុងឆ្នាំ ២០១៨ និងដើមឆ្នាំ ២០១៩។ ខេត្តពោធិ៍សាត់ ជាខេត្តក្រីក្រមួយនៅប៉ែកពាយព្យនៃប្រទេសកម្ពុជា។ ខេត្តនេះមានស្រុកចំនួន ៦ ឃុំចំនួន ៤៩ និងភូមិចំនួន ៥០៥។[១] ការសិក្សាដំបូងបានធ្វើឡើងនៅក្នុងស្រុកបាកាណ វាលវែង និងក្រវាញ។

ការសិក្សានេះធ្វើឡើងនៅក្នុងភូមិចំនួន ១២១ ក្នុងស្រុកកណ្តៀង ក្រគរ និងក្រុងពោធិ៍សាត់។ យើងព្យាយាមសម្ភាសមនុស្សឲ្យបានចំនួនប្រហាក់ប្រហែលគ្នានៅតាមស្រុកនីមួយៗ។




[១] គិតត្រឹមឆ្នាំ ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកខេត្តនេះដល់ទៅ ៧ ស្រុក និង ៥១១ ភូមិ។

## ចំនួនអ្នកផ្តល់ចម្លើយ




ការសិក្សានេះមានអ្នកឆ្លើយសំណួរចំនួន ៤២២ នាក់ ក្នុងនោះ មានស្ត្រីចំនួន ១៦៦ នាក់ និងបុរសចំនួន ២៥៦ នាក់។

## ភេទអ្នកផ្តល់ចម្លើយ




## ប្រភេទនៃពិការភាព

ដើម្បីវាស់ស្ទង់អំពីពិការភាព យើងប្រើកម្រងសំណួរដែលមានឈ្មោះថា The Washington Group Set។[២] កម្រងសំណួរទាំងនេះទាក់ទងទៅនឹងភាពលំបាកជាក់ស្តែងក្នុងការធ្វើសកម្មភាពមួយចំនួន ដូចជាការពិបាកក្នុងការមើល ឬស្តាប់របស់អ្នកផ្តល់ចម្លើយ។

សំណួរមានដូចជា៖

១. តើអ្នកពិបាកមើលដែរឬទេ បើទោះជាអ្នកពាក់វ៉ែនតាក៏ដោយ?
២. តើអ្នកពិបាកស្តាប់ដែរឬទេ បើទោះជាអ្នកប្រើឧបករណ៍ជំនួយការស្តាប់ក៏ដោយ?
៣. តើអ្នកពិបាកដើរចុះ ឬឡើងជណ្តើរឬទេ?
៤. តើអ្នកមានបញ្ហាក្នុងការចងចាំ ឬការផ្តង់អារម្មណ៍ដែរឬទេ?
៥. តើអ្នកមានការពិបាកក្នុងការមើលថែទាំខ្លួនឯងដូចជាការបោកខោអាវ ឬស្លៀកពាក់ដែរឬទេ?
៦. នៅពេលអ្នកនិយាយស្តីតាមទម្លាប់ធម្មតារបស់អ្នក តើអ្នកមានការលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នាដែរឬទេ ឧ.ស្តាប់គេយល់ និងគេស្តាប់អ្នកយល់?

ចំពោះអ្នកដែលនិយាយថាពួកគាត់មានការពិបាកច្រើនក្នុងការធ្វើសកម្មភាពអ្វីមួយ ឬមិនអាចធ្វើសកម្មភាពនោះបានសោះ គេចាត់ទុកគាត់ថាគាត់ជាជនមានពិការភាពនៃផ្នែកនោះតែម្តង។ ពួកគាត់អាចមានភាពលំបាកក្នុងការធ្វើសកម្មភាពច្រើនជាងមួយប្រភេទ (ឧ.មិនអាចឮទាល់តែសោះ ហើយមានការលំបាកខ្លាំងក្នុងការធ្វើទំនាក់ទំនង)។

## អ្នកផ្តល់ចម្លើយដែលសមត្ថភាពសម្បទារបស់គាត់មានកម្រិត




[២] វ៉ាស៊ិនតោនគ្រុប (The Washington Group Set) ផ្តោតសំខាន់ទៅលើការលំបាកកាយសម្បទា (ថាតើនរណាម្នាក់មានការលំបាកក្នុងការធ្វើសកម្មភាពណាមួយ) ជាជាងថាតើនរណាម្នាក់ស្គាល់ខ្លួនឯងថាជាជនមានពិការភាព។ អ្នកឆ្លើយសំណួរអាចជ្រើសរើសជម្រើសបួន នៅពេលឆ្លើយសំណួរ ដូចជា មានការលំបាកខ្លះៗ លំបាកខ្លាំង ឬមិនអាចធ្វើបាន។

## អាយុ




## កម្រិតអប់រំ ឬអក្ខរកម្ម




## មុខរបរ




### តើយើងសម្គាល់ជនមានពិការភាពទាំងអស់នោះដោយរបៀបណា ?

យើងកំណត់អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយដោយការសាកសួរមេភូមិ មេឃុំ និងអ្នកភូមិ ពីទីកន្លែងរស់នៅរបស់ជនមានពិការភាពក្នុងសហគមន៍ ហើយយើងធ្វើការសម្ភាសជនមានពិការភាពទាំងនោះនៅផ្ទះរបស់គាត់រៀងៗខ្លួន។

# ជាធម្មតា តើជនមានពិការភាពទទួលព័ត៌មានដោយរបៀបណា ?

ផ្នែកនេះរៀបរាប់ពីរបៀបដែលជនមានពិការភាពទទួលបានព័ត៌មានអំពីប្រធានបទផ្សេងៗ

យើងចាប់អារម្មណ៍ក្នុងការស្វែងយល់ពីមធ្យោបាយដែលជនមានពិការភាពទទួលបានព័ត៌មានទាក់ទងនឹងសកម្មភាពផ្សេងៗនៅក្នុងសហគមន៍។ យើងសួរពួកគាត់ថា តើគាត់ទទួលបានព័ត៌មានអំពីប្រធានបទនានាដូចជា ការប្រជុំ ការបោះឆ្នោត សុខភាព ការកម្សាន្ត ការប្រជុំផ្លូវការ ស្ថានភាពអាសន្ន ឱកាសការងារ ពិការភាព និងសិទ្ធិមនុស្សដោយរបៀបណា។

ជនមានពិការភាពបាននិយាយថា មានច្រើនករណីណាស់ ដែលពួកគាត់មិនដែលបានទទួលព័ត៌មានពីប្រធានបទទាំងនោះទេ។ អាជ្ញាធរមូលដ្ឋានត្រូវបានចាត់ទុកថាមានតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មាននៅក្នុងសហគមន៍។ ក្តារបិទផ្សាយព័ត៌មានក្នុងភូមិ ការប្រកាសព័ត៌មានដោយប្រើឧបករណ៍បំពងសម្លេង ឬប្រព័ន្ធផ្សព្វផ្សាយដូចជា ហ្វេសប៊ុក ឬក៏ទូរស័ព្ទចល័ត មិនត្រូវបានលើកឡើងថាជាប្រភពព័ត៌មានសំខាន់ឡើយ។

## ការប្រជុំ




- គ្រួសារ
- ឧបករណ៍បំពងសម្លេង
- ទូរទស្សន៍
- ក្តារបិទផ្សាយព័ត៌មាន
- ទូរស័ព្ទចល័ត
- បុគ្គលិកសុខាភិបាល
- វិទ្យុ
- អង្គការក្រៅរដ្ឋាភិបាល
- សមាជិកសហគមន៍
- ហ្វេសប៊ុក
- អាជ្ញាធរមូលដ្ឋាន
- មិនដែលទទួលបានព័ត៌មាន

## សុខភាព




## ការបោះឆ្នោត




## ការកម្សាន្ត ឬកីឡា




## ឯកសារផ្លូវការ




"ព័ត៌មាននានាមានទិសដៅសម្រាប់តែសមាជិកគ្រួសារដែលមានកាយសម្បទាធម្មតា ហើយមិនពាក់ព័ន្ធជាមួយជនមានពិការភាពឡើយ"

"ព័ត៌មាននានាមិនពាក់ព័ន្ធជាមួយជនមានពិការភាពទេ"

"គេបានមកជូនដំណឹងដល់សមាជិកគ្រួសារដែលមិនមានពិការភាព"

"មន្ត្រីប៉ូលីសបានមកជូនដំណឹងដោយផ្ទាល់"



## ភាពអាសន្ន និងគ្រោះមហន្តរាយ




"ខ្ញុំទទួលបានព័ត៌មាន ហើយប៉ុន្តែមិនច្បាស់លាស់នោះទេដោយសារពិការភាពរបស់ខ្ញុំ"។

## ពិការភាព




"ខ្ញុំដឹងតាមរយៈជនមានពិការភាពដូចខ្ញុំដែរ"។

"ខ្ញុំមានពិការភាព (ថ្លង់) ដូច្នេះខ្ញុំមិនអាចទទួលបានព័ត៌មាន ហើយព័ត៌មានក៏មិនងាយស្រួលយល់ដែរសម្រាប់ខ្ញុំ"។

## ការងារ




## សិទ្ធិមនុស្ស



# ហេតុអ្វីបានជាប្រភពព័ត៌មានមួយចំនួនមានសារៈសំខាន់?

ផ្នែកនេះរៀបរាប់អំពីមូលហេតុដែលប្រភពព័ត៌មានទូទៅខ្លះមានប្រយោជន៍ ឬគ្មានប្រយោជន៍សម្រាប់ជនមានពិការភាព។



មធ្យោបាយងាយស្រួលក្នុងការទទួលបានព័ត៌មាន

វាមិនសមស្របតាមតម្រូវការរបស់ខ្ញុំ

យើងបានសាកសួរជនមានពិការភាពថា ហេតុអ្វីបានជាប្រភពព័ត៌មានខ្លះមានប្រយោជន៍ ហើយខ្លះទៀតគ្មានប្រយោជន៍សម្រាប់ពួកគាត់ក្នុងការទទួលបានព័ត៌មាន។

## ទូរទស្សន៍

"ខ្ញុំមានទូរទស្សន៍នៅផ្ទះ ហើយការចាក់ផ្សាយព័ត៌មានមានពេលវេលាកំណត់ច្បាស់លាស់។ ព័ត៌មានតាមទូរទស្សន៍មានតាមតម្រូវការ ហើយងាយស្រួសក្នុងការមើលនៅផ្ទះ។ ទូរទស្សន៍ជាប្រភពព័ត៌មានច្បាស់លាស់ដែលខ្ញុំអាចទទួលបានព័ត៌មានដោយផ្ទាល់។"



ខ្ញុំមិនមើលទូរទស្សន៍ទៀងទាត់នោះទេ ដូច្នេះខ្ញុំខកខានមើលការផ្សាយខ្លះ។ ពេលខ្លះខ្ញុំមិនដឹងថា គួរមើលពេលណាដើម្បីទទួលបានព័ត៌មានដែលខ្ញុំត្រូវការនោះទេ ហើយពេលខ្លះទៀតខ្ញុំចូលមកមើលពាក់កណ្តាលកម្មវិធីទៅហើយ។ ម្យ៉ាងទៀត ការចាក់ផ្សាយលឿនពេកសម្រាប់ខ្ញុំ ដូច្នេះហើយ ខ្ញុំមិនអាចចាប់យកព័ត៌មានដែលពាក់ព័ន្ធទាំងអស់នោះបានទេ។ ខ្ញុំឃើញព័ត៌មានលើទូរទស្សន៍ ប៉ុន្តែខ្ញុំមិនយល់ពីវាសោះ ព្រោះថាព័ត៌មានទាំងនោះលឿនពេកសម្រាប់ខ្ញុំ ហើយវាពិបាកយល់ណាស់ សម្រាប់មនុស្សថ្លង់ដូចខ្ញុំ។

## វិទ្យុ

ព័ត៌មានដែលប្រកាសតាមវិទ្យុមានភាពច្បាស់លាស់។ ខ្ញុំមានវិទ្យុនៅផ្ទះ ខ្ញុំអាចទទួលបានព័ត៌មាននៅផ្ទះតែម្តង។ វាពិតជាងាយស្រួលណាស់ព្រោះខ្ញុំអាចបើកវិទ្យុស្តាប់ដោយខ្លួនឯងបាន។



ខ្ញុំមិនបានស្តាប់វិទ្យុគ្រប់ពេលទេ ដូច្នេះខ្ញុំមិនដឹងពីការផ្តល់ព័ត៌មានតាមរយៈវិទ្យុឡើយ ហើយជួនកាលវាមានភាពរអាក់រអួល។ ពេលខ្លះគេប្រកាសព័ត៌មានលឿនពេក អញ្ចឹងហើយខ្ញុំមិនយល់នោះទេ។ ចំណែកពេលខ្លះទៀត ខ្ញុំខកខានមិនបានស្តាប់ព័ត៌មានទេ ព្រោះគេប្រកាសព័ត៌មានតែម្តងក្នុងមួយថ្ងៃ។ មួយវិញទៀត រលកធាតុអាកាសអាចមានការរអាក់រអួល។

## គ្រួសារ

សម្រាប់ខ្ញុំ ការទទួលបានព័ត៌មានមិនពិបាកទេព្រោះម្តាយ ឬក្មួនៗខ្ញុំនិងសមាជិកគ្រួសារខ្ញុំពន្យល់ប្រាប់ខ្ញុំយ៉ាងច្បាស់។ ពួកគាត់បានប្រាប់ខ្ញុំនូវអ្វីដែលត្រូវធ្វើយ៉ាងច្បាស់ ហើយខ្ញុំអាចធ្វើការសន្ទនាជាមួយគ្នាបាន។ ខ្ញុំអាចទុកចិត្តពួកគាត់បាន។



គ្រួសារខ្ញុំមិនទាំងដឹងព័ត៌មានដោយខ្លួនឯងរហូតផង។ សមាជិកគ្រួសារអាចប្រាប់បានតែអ្វីដែលពួកគាត់ដឹង ហើយអ្វីដែលគាត់បានដឹងវាមិនច្បាស់ ឬមិនអាចជឿជាក់បាន។ វាជាការលំបាកសម្រាប់សមាជិកគ្រួសាររបស់ខ្ញុំក្នុងការទាក់ទងជាមួយខ្ញុំ ព្រោះខ្ញុំប្រើភាសាសញ្ញាហើយខ្ញុំមានបញ្ហាខ្សោយបញ្ញា។ រាល់ព័ត៌មានដែលខ្ញុំទទួលបានមិនច្បាស់ការណ៍នោះទេ ពីព្រោះជាព័ត៌មានតាមការនិយាយតៗគ្នា។

## អាជ្ញាធរមូលដ្ឋាន

មេភូមិអញ្ជើញខ្ញុំដោយផ្ទាល់តាមរយៈទូរស័ព្ទ ឬមកដល់ផ្ទះ។មេភូមិបានមកដល់ផ្ទះខ្ញុំផ្ទាល់ ដើម្បីប្រាប់យើងឲ្យច្បាស់អំពីពេលវេលា និងទីកន្លែង។ គាត់មកទៀងពេលហើយបានផ្តល់ព័ត៌មានយ៉ាងច្បាស់លាស់។ មេភូមិបានពន្យល់ដោយប្រើភាសាសាមញ្ញ និងភាសាសញ្ញា។ គាត់ពន្យល់គ្រប់យ៉ាងមកខ្ញុំដោយផ្ទាល់ ហើយគេប្រកាសព័ត៌មានជាសាធារណៈ។



ពេលខ្លះគ្មាននរណាម្នាក់មកជូនដំណឹងខ្ញុំដល់ផ្ទះនោះទេ។ ជួនកាលព័ត៌មានមិនពេញលេញ ហើយហាក់ដូចជាពួកគេមិនបានប្រាប់ព័ត៌មានទាំងអស់។ យូរៗម្តងទើបគេមកប្រាប់ព័ត៌មាន ហើយគេប្រាប់ជាពាក្យសម្តី ពេលខ្លះពួកគេភ្លេចប្រាប់ព័ត៌មានតែម្តង ឬជួនកាលបាត់ព័ត៌មានខ្លះ ដោយសារការប្រាប់តៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ខ្ញុំមិន អាចធ្វើការទាក់ទងជាមួយពួកគាត់បានទេ ដោយសារតែខ្ញុំថ្លង់ ពិការសតិបញ្ញា ពិបាកមើល ហើយក៏មិនអាចមើលឃើញអ្នកមកជូនដំណឹងបានទេ។ មួយវិញទៀត ចំណេះដឹងរបស់មេភូមិ និងការយល់ដឹងពីបញ្ហាពិការភាពរបស់គាត់មានកម្រិត ដូច្នេះការពន្យល់របស់គាត់អំពីសេវាកម្មផ្សេងៗដល់ជនមានពិការភាពមិនបានស៊ីជម្រៅនោះទេ។

### តើអ្នកធ្វើយ៉ាងណា ដើម្បីងាយស្រួលក្នុងការទទួលបានព័ត៌មាន ?

- មធ្យោបាយងាយស្រួលគឺ ត្រូវចែករំលែកព័ត៌មានឲ្យបានទូលំទូលាយ និងឲ្យបានញឹកញាប់ហើយគួររៀបចំព័ត៌មានសម្រាប់ផ្សព្វផ្សាយឲ្យបានពីរ ឬបីថ្ងៃមុនធ្វើការផ្សព្វផ្សាយ ព្រមទាំងកំណត់ទីតាំងឲ្យបានច្បាស់លាស់ ឬបើអាច គួររៀបចំលិខិតអញ្ជើញគាត់កាន់តែប្រសើរ។
- សម្រាប់ជនមានការពិបាកក្នុងការស្តាប់ (ថ្លង់) ពួកគាត់គួរតែទទួលបានព័ត៌មានផ្ទាល់ និងប្រើភាសាសញ្ញា។
- មកជូនដំណឹងដោយផ្ទាល់ និងមិនប្រញាប់ប្រញាល់។
- គួរផ្តល់អាទិភាពដល់ជនមានពិការភាព ដើម្បីឲ្យគាត់ទទួលបានព័ត៌មាន។
- មធ្យោបាយងាយស្រួលក្នុងការជូនដំណឹងដល់ពួកគាត់គឺតាមរយៈឪពុកម្តាយរបស់ពួកគាត់ដែលចេះភាសាសញ្ញា។
- ជូនដំណឹងសំខាន់ៗដែលពាក់ព័ន្ធដល់ជនមានពិការភាពនៅផ្ទះគាត់ផ្ទាល់។



# ការទទួលបានព័ត៌មានពីរាជរដ្ឋាភិបាល

ផ្នែកនេះរៀបរាប់ពីការទទួលបានព័ត៌មាន និងយល់ដឹងពីព័ត៌មានដែលចេញពីរាជរដ្ឋាភិបាល។

តើអ្នកធ្លាប់ជួបប្រទះបញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានដែលផ្សព្វផ្សាយដោយរដ្ឋាភិបាលដែរឬទេ ?

យើងបានសាកសួរជនមានពិការភាព ថាតើពួកគាត់មានការលំបាកអ្វីខ្លះក្នុងការទទួលបានព័ត៌មានពីរាជរដ្ឋាភិបាល។ ជនមានពិការភាពចំនួន ១៥៤ នាក់ក្នុងចំណោម ៤២២ នាក់បាននិយាយថា ពួកគាត់ធ្លាប់បានជួបបញ្ហាប្រឈមមែន។ តាមរយៈបទពិសោធន៍កន្លងមក ស្ត្រីដែលមានពិការភាពជួបការលំបាកជាងបុរស។ អ្នកមានការពិបាកក្នុងការប្រាស្រ័យទាក់ទងជួបបញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានជាងអ្នកដែលពិបាកក្នុងការមើល និងអ្នកដែលពិបាកផ្លាស់ទី។ កុមារនិងចាស់ជរាមានភាពលំបាកក្នុងការទទួលបានព័ត៌មានជាងមនុស្សដែលមានអាយុចន្លោះពី ៥០ ទៅ ៧០ ឆ្នាំ។




## បញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានរបស់ជនមានពិការភាព



# បញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានដោយសារអាយុ




ចំពោះអ្នកផ្ដល់ចម្លើយដែលនិយាយថា ពួកគាត់មានបញ្ហាប្រឈមក្នុងការទទួលបានព័ត៌មានពីរដ្ឋាភិបាល យើងបានសួរបន្ថែមថា ហេតុអ្វីបានជាមានភាពលំបាកសម្រាប់ពួកគាត់។

## ចម្លើយរបស់គាត់រួមមាន

- ព័ត៌មានដែលផ្ដល់ដោយអាជ្ញាធរមូលដ្ឋានត្រូវបានរៀបចំដោយបុគ្គលដែលមិនមានពិការភាព។
- ព័ត៌មានពុំបានផ្ដល់ជូនដល់ជនមានពិការភាពដោយផ្ទាល់នោះទេ គេបានត្រឹមផ្ដល់ព័ត៌មានទៅឲ្យក្រុមគ្រួសាររបស់គាត់តែប៉ុណ្ណោះ។
- ភាគច្រើន គេប្រាប់ព័ត៌មានតៗគ្នាពីម្នាក់ទៅម្នាក់ ដែលធ្វើឲ្យបាត់បង់អត្ថន័យព័ត៌មាន។
- ពេលខ្លះ ការអញ្ជើញឲ្យចូលរួមប្រជុំ គឺធ្វើតាមរយៈការស្រែកប្រកាសពីចម្ងាយ ឬផ្ដាំតាមរយៈមនុស្សដទៃទៀត ដែលធ្វើឲ្យជនមានពិការភាពពិបាកទទួលបានព័ត៌មាន។
- ព័ត៌មានប្រាប់តៗគ្នា ដែលនាំឲ្យបាត់បង់ន័យដើម។
- ភាគច្រើន គេមិនអញ្ជើញខ្ញុំទេព្រោះគេគិតថាជនមានពិការភាពដូចខ្ញុំពិបាកធ្វើដំណើរ។

ជនមានពិការភាពភាគច្រើននិយាយថា ពួកគាត់មានភាពលំបាកក្នុងការទទួលបានព័ត៌មានដែលចែករំលែកដោយរាជរដ្ឋាភិបាល។ លើសពីនេះទៅទៀត ជនមានពិការភាពទាំងនោះនិយាយថា ពួកគាត់មិនអាចប្រាប់ពីបញ្ហារបស់ពួកគាត់ដល់អ្នកណាម្នាក់បានឡើយ។

តើអ្នកទៅជួបនរណាដើម្បីដោះស្រាយបញ្ហារបស់អ្នក?



# ការចូលរួម

# ព្រឹត្តិការណ៍សង្គម

ផ្នែកនេះពិនិត្យមើលថាតើជនមានពិការភាពបានចូលរួមក្នុងសកម្មភាពសង្គម និងចូលរួមជាមួយអ្នកដទៃនៅក្នុងសហគមន៍ដែរឬទេ។

## កាលពីឆ្នាំមុន តើជនមានពិការភាពបានចូលរួមក្នុងកម្មវិធីណាខ្លះនៅក្នុងសហគមន៍?

ជនមានពិការភាពដែលជាបុរសបានចូលរួមកម្មវិធីមួយចំនួនដូចជាពិធីអាពាហ៍ពិពាហ៍ បុណ្យទានផ្សេងៗ និងការបោះឆ្នោតច្រើនជាងជនមានពិការភាពជាស្ត្រី។ ជនមានពិការភាពសតិបញ្ញាបានចូលរួមក្នុងសកម្មភាពសង្គមតិចជាងគេ។ ចំណែកអ្នកដែលពិបាកក្នុងការផ្លាស់ទីឬពិបាកក្នុងការមើល ពួកគាត់ ចូលរួមសកម្មភាពសង្គមច្រើនជនមានពិការភាពផ្សេងៗទៀត។









## ចូលរួមបុណ្យសព




## ចូលរួមបោះឆ្នោត




៣នាក់ ក្នុងចំណោម ៤នាក់នៃជន
ដែលពិបាកផ្លាស់ទី ឬពិបាកក្នុងការ
មើលបានចូលរួមបោះឆ្នោត។
ចំណែកឯមនុស្សថ្លង់ មានបញ្ហាសតិ
បញ្ញា ឬពិបាកទំនាក់ទំនងវិញ ក្នុង
ចំណោម ៤នាក់ មានតែម្នាក់
ប៉ុណ្ណោះដែលបានចូលរួម។

# ការចូលរួមប្រជុំ

ផ្នែកនេះផ្តោតសំខាន់ទៅលើការចូលរួមប្រជុំផ្សេងៗដែលធ្វើឡើងក្នុងសហគមន៍របស់ជនមានពិការភាព

នៅក្នុងសហគមន៍ គេបានរៀបចំការប្រជុំជាច្រើនក្នុងមួយឆ្នាំៗ ដូចជា ការប្រជុំស្តីពីផែនការអភិវឌ្ឍឃុំសង្កាត់ ឬការជួបជុំជាមួយមេដឹកនាំដែលជាប់ឆ្នោតថ្មីៗ។ ការប្រជុំទាំងនេះធ្វើឡើងសម្រាប់ប្រជាជនទូទៅក្នុងសហគមន៍ ហើយវាជាវេទិកាសម្រាប់ប្រជាជនធ្វើការចែករំលែក លើកឡើងពីបញ្ហាប្រឈមនានា ព្រមទាំងធ្វើការបញ្ចេញមតិយោបល់ផ្សេងៗដើម្បីអភិវឌ្ឍសហគមន៍។

ជនមានពិការភាពភាគច្រើនមិនបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗនោះទេក្នុងរយៈពេល ១២ខែចុងក្រោយនេះ។

ក្នុងរយៈពេល ១២ខែចុងក្រោយនេះ តើអ្នកបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗដែរ ឬទេ ?




## ទីតាំងប្រជុំ

តើជនមានពិការភាពដែលបានទៅចូលរួមប្រជុំមានការលំបាកក្នុងការទៅប្រជុំ ឬចូលទៅកាន់ទីតាំងប្រជុំដែរឬទេ ? ៣ នាក់ ក្នុងចំណោម ៤ នាក់និយាយថា មានការលំបាក ព្រោះពួកគាត់ពិបាកធ្វើដំណើរទៅកាន់ទីតាំងប្រជុំ។ អ្នកដែលឆ្លើយថាគ្មានការលំបាក ដោយសារទីតាំងប្រជុំនៅក្បែរផ្ទះរបស់គាត់ ឬដោយសារគាត់មានអ្នកដឹកទៅប្រជុំ។

តើអ្នកមានការលំបាកក្នុងការទៅប្រជុំ ឬចូលទៅក្នុងទីតាំងប្រជុំដែរឬទេ ?



ជនមានពិការភាពភាគច្រើនដែលមិនបានចូលរួមប្រជុំនិយាយថា ពួកគាត់មិនបានចូលរួមប្រជុំដោយសារតែកត្តាពិការភាពរបស់គាត់។ ហេតុផលផ្សេងទៀតមានដូចជា៖

“គេមិនអញ្ជើញខ្ញុំដោយសារអ្នករៀបចំកម្មវិធីយល់ថា វាពិបាកក្នុងការដាក់បញ្ចូលជនមានពិការភាពក្នុងកិច្ចប្រជុំ”

“ខ្ញុំមិនបានទទួលព័ត៌មានទាន់ពេលវេលាទេ ដូច្នេះ ខ្ញុំមិនបានដឹងថាមានការប្រជុំឡើយ។”

តើគេបានរាប់បញ្ចូលមតិយោបល់របស់អ្នក ទៅក្នុងការសម្រេចចិត្តណាមួយដែរឬទេ ?




ភាគច្រើន មេភូមិបានផ្តល់ព័ត៌មានដល់ប្រជាជនដោយផ្ទាល់ ឬតាមរយៈការចូលរួមប្រជុំមុនៗ។ ដូច្នេះ មេភូមិដើរតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មានក្នុងសហគមន៍។ មេភូមិគួរតែស្គាល់ជនមានពិការភាពក្នុងភូមិ ទីតាំងរស់នៅរបស់ពួកគាត់ ហើយនឹងរបៀបដែលអាចទៅរកពួកគាត់ឃើញ។

ទោះបីនៅពេលដែលជនមានពិការភាពបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗពិតមែន ប៉ុន្តែគាត់ពុំបានចូលរួមចែករំលែកមតិយោបល់ ឬចូលរួមធ្វើការសម្រេចចិត្តណាមួយឡើយ។

# ការទទួលបាននិង
# កម្មសិទ្ធិលើឯកសារផ្លូវការ

ផ្នែកនេះ សង្កត់ធ្ងន់ទៅលើភាពជាម្ចាស់នៃឯកសារផ្លូវការរបស់ជនមានពិការភាព

ឯកសារផ្លូវការមួយចំនួនដូចជា សំបុត្រកំណើត សៀវភៅគ្រួសារ ប្លង់ដី ឬអត្តសញ្ញាណប័ណ្ណ គឺផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ហើយវាមានសារៈសំខាន់សំរាប់ការរស់នៅ។ ការសិក្សានេះផ្តោតទៅលើភាពខុសគ្នារវាងភាពជាម្ចាស់លើឯកសារនីមួយៗរបស់ជនមានពិការភាពប្រភេទផ្សេងៗគ្នា។

## អត្តសញ្ញាណប័ណ្ណ

ភាគច្រើន អ្នកដែលពិបាកក្នុងការមើល ឬពិបាកផ្លាស់ទីមានអត្តសញ្ញាណប័ណ្ណ ប៉ុន្តែ ១ ភាគ ៣ ប៉ុណ្ណោះនៃជនពិការសតិបញ្ញាមានអត្តសញ្ញាណប័ណ្ណ ។

## ជនមានពិការភាពប្រហែល 20% ដែលគ្មានអត្តសញ្ញាណប័ណ្ណ

### មូលហេតុចម្បងដែលពួកគេគ្មានអត្តសញ្ញាណប័ណ្ណ




- គេមិនអាចធ្វើអត្តសញ្ញាណប័ណ្ណឲ្យគាត់បានទេ ព្រោះគាត់គ្មានមេដៃសម្រាប់ផ្តិតស្នាមមេដៃ។
- អត្តសញ្ញាណប័ណ្ណមិនសំខាន់ទេ ព្រោះគាត់ជាមនុស្សថ្លង់។
- គាត់គិតថា ដោយសារតែគាត់ជាជនមានពិការភាពដូច្នេះគ្មានអ្នកណាធ្វើអត្តសញ្ញាណប័ណ្ណឲ្យគាត់ទេ។
- អាជ្ញាធរមូលដ្ឋានមិនបានធ្វើអត្តសញ្ញាណប័ណ្ណឲ្យគាត់ទេ ព្រោះគាត់មានការពិបាកក្នុងការមើល។

### ភាគរយដែលជនមានពិការភាពគ្មានអត្តសញ្ញាណប័ណ្ណ



# ប័ណ្ណសមធម៌ ឬប័ណ្ណក្រីក្រ

នៅប្រទេសកម្ពុជា កម្មវិធីប័ណ្ណសមធម៌ ជាកម្មវិធីថ្នាក់ជាតិមួយសម្រាប់កំណត់សម្គាល់គ្រួសារក្រីក្រ។ គេផ្តល់ប័ណ្ណសមធម៌ដល់គ្រួសារក្រីក្រ ដើម្បីឲ្យពួកគាត់អាចទទួលបានសេវាសាធារណៈមួយចំនួនដូចជា ការពិគ្រោះយោបល់ និងសេវាកម្មសុខភាពដោយឥតគិតថ្លៃ។

ការកំណត់រកគ្រួសារក្រីក្ររៀបចំឡើងដោយឲ្យគាត់បំពេញក្នុងកម្រងសំណួរចម្លើយស្តង់ដាមួយ។

អ្នកផ្តល់ចម្លើយតិចជាងពាក់កណ្តាលមានប័ណ្ណសមធម៌។

## ជនមានពិការភាព ៥៨ ភាគរយគ្មានប័ណ្ណសមធម៌

### ហេតុផលចម្បងដែលជនមានពិការភាពពុំមានប័ណ្ណសមធម៌ ឬប័ណ្ណក្រីក្រ




### ភាគរយជនមានពិការភាពដែលពុំមានប័ណ្ណសមធម៌តាមប្រភេទនៃពិការភាព



ជនមានពិការភាពចំនួន១១% ពុំមានសំបុត្រកំណើត

មូលហេតុចម្បងដែលគាត់ពុំមានសំបុត្រកំណើត

១ ខ្ញុំគិតថាវាមិនចាំបាច់ត្រូវមាននោះទេ។

២ ខ្ញុំមិនបានចុះឈ្មោះ



"អ្នកពិការសតិបញ្ញាមិនអាចទៅចុះឈ្មោះបានទេ។"

"ឪពុកម្តាយរបស់ខ្ញុំបានស្លាប់ ហើយខ្ញុំមិនដឹងថាបានធ្វើវាឬក៏អត់។"

## ភាគរយជនមានពិការភាពដែលគ្មានសំបុត្រកំណើតតាមប្រភេទនៃពិការភាព



## ជនមានពិការភាពចំនួន ៣៤% ពុំមានប័ណ្ណបោះឆ្នោត

### មូលហេតុចម្បងដែលពួកគាត់ពុំមានប័ណ្ណបោះឆ្នោត

១ ខ្ញុំមិនអាចមានវាទេ ដោយសារខ្ញុំជាជនមានពិការភាព

២ ខ្ញុំគិតថាវាមិនចាំបាច់ត្រូវមានវា



៣ ខ្ញុំមិនដែលឮពីវាសោះ

៤ ខ្ញុំអត់មានពេលធ្វើវាសោះ

"ខ្ញុំជាមនុស្សថ្លង់ ដូច្នេះមិនអាចទៅបោះឆ្នោតបានទេ"

"ខ្ញុំមិនអាចផ្លាស់ទី ឬដើរបាន ដូច្នេះ ខ្ញុំមិនបំពេញលក្ខខណ្ឌណាមួយឡើយ។

ដោយសារពិការភាព ខ្ញុំមិនអាចចូលរួមបាន"

### ភាគរយដែលគ្មានប័ណ្ណបោះឆ្នោត តាមប្រភេទនៃពិការភាព



# បញ្ហាប្រឈមក្នុងការទទួលបានសេវាកម្មសាធារណៈ

ផ្នែកនេះរៀបរាប់អំពីការលំបាកក្នុងការទទួលបានសេវាកម្មសាធារណៈរបស់ជនមានពិការភាព

សេវាកម្មសាធារណៈ គឺជាសេវាកម្មដែលរដ្ឋាភិបាលផ្ដល់ជូន ប្រជាពលរដ្ឋ ដូចជា សេវាថែទាំសុខភាព ទឹកភ្លើង ការអប់រំ ឬសេវាកម្មសង្គ្រោះបន្ទាន់។

ជនមានពិការភាពម្នាក់ក្នុងចំណោម ៤នាក់បាននិយាយថា ពួកគាត់បានជួបប្រទះបញ្ហាប្រឈមក្នុងការទទួលបានសេវាសាធារណៈនៅកំឡុងរយៈពេល ១២ខែកន្លងមកនេះ។



## តើអ្នកទៅជួបនរណា ដើម្បីដោះស្រាយបញ្ហានេះ?

មនុស្សមួយចំនួនបាននិយាយថាពួកគេនឹងរៀបរាប់ប្រាប់អាណាព្យាបាល សមាជិកគ្រួសារ បុគ្គលិកសុខាភិបាល ឬអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ៩៤% នៃមនុស្សទាំងអស់នោះបាននិយាយថា ពួកគេមិនបានប្រាប់នរណាម្នាក់ឡើយអំពីបញ្ហាប្រឈមរបស់ខ្លួន។



## ហេតុផលនៃបញ្ហាប្រឈមទាំងនោះរួមមាន៖

ជនមានពិការភាពទទួលបានការយកចិត្តទុកដាក់តិចតួចបំផុត ឧ. អំឡុងពេលព្យាបាល បុគ្គលិកសុខាភិបាលពុំបានយកចិត្តទុកដាក់លើមនុស្សថ្លង់ទេ ដោយសារថ្លង់ធ្វើឲ្យពិបាកទំនាក់ទំនង។

វាមិនងាយស្រួលក្នុងការទទួលបានសេវាសាធារណៈ នៅពេលដែលពួកគាត់ទៅមន្ទីរពេទ្យ ក្រុមគ្រូពេទ្យបានសួររកប័ណ្ណក្រីក្រ។

គ្មានការយកចិត្តទុកដាក់ពីអ្នកផ្ដល់សេវា។
គ្មានការផ្ដល់ព័ត៌មានដល់ជនមានពិការភាព។
គ្មានព័ត៌មានពីសេវាកម្ម ឬពុំដឹងពីសេវាកម្ម។

# ការស្នើសុំទៅអាជ្ញាធរ

ផ្នែកនេះរៀបរាប់ពីការធ្វើសំណើសុំផ្សេងៗទៅអាជ្ញាធរមូលដ្ឋានរបស់ជនមានពិការភាព




នៅក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងពិភាក្សាអំពីតម្រូវការរបស់ពួកគេជាមួយរដ្ឋាភិបាល។ ជារឿយៗ មេភូមិគឺជាមនុស្សដំបូងដែល ប្រជាពលរដ្ឋអាចទាក់ទងបាន។ ប្រជាពលរដ្ឋអាចធ្វើសំណើទៅកាន់រដ្ឋាភិបាលពីតម្រូវការរបស់ពួកគាត់ដូចជា ការជួសជុល តម្រូវការចាំបាច់ សេវាកម្មសុខភាព ជំនួយផ្នែកអាជីវកម្មជាដើម។ ប្រជាពលរដ្ឋក៏អាចធ្វើសំណើសុំទៅកាន់អាជ្ញាធរមូលដ្ឋានផ្ទាល់មាត់បានផងដែរ។

អ្នកឆ្លើយសំណួរចំនួន ៣៦ នាក់ ក្នុងចំណោម ៤២២ នាក់ បាននិយាយថាពួកគេបានដាក់សំណើ ឬរាយការណ៍អំពីបញ្ហាកាលពីឆ្នាំកន្លងទៅ។ សំណើទាំងនោះបានធ្វើការស្នើសុំទៅកាន់៖




ក្នុងចំណោមសំណើរទាំង ៣៦ មានសំណើរ ២៧ បានធ្វើឡើងទៅកាន់រដ្ឋបាល ( ថ្នាក់ភូមិ ឃុំ ស្រុក និងខេត្ត )។ ការស្នើសុំភាគច្រើនធ្វើឡើងទៅកាន់អាជ្ញាធរមូលដ្ឋាននៅថ្នាក់ភូមិ ទោះបីជាការសម្រេចចិត្តភាគច្រើនធ្វើឡើងនៅថ្នាក់ខេត្តក៏ដោយ។

មនុស្សពីរនាក់បាននិយាយថា ពួកគេបានបំពេញសំណុំបែបបទ ដើម្បីធ្វើការស្នើសុំ តែអ្នកផ្សេងទៀតបាននិយាយថា ពួកគាត់បានស្នើសុំទៅអាជ្ញាធរផ្ទាល់មាត់។

## តើមានសំណើអ្វីខ្លះដែលអ្នកឆ្លើយសំណួរបានស្នើទៅកាន់រដ្ឋាភិបាល?

- ✓ អាហារ
- ✓ អង្ករ
- ✓ សំណង់លំនៅដ្ឋាន
- ✓ សិក្ខាសាលាអំពីការថែទាំនិងជួសជុលកង់
- ✓ ថវិកាសម្រាប់សង្គ្រោះបន្ទាន់លើសុខភាពកុមារ
- ✓ បំណែកដីភូមិ
- ✓ រទេះជនមានពិការភាព
- ✓ ការជួសជុលផ្លូវ
- ✓ ឧបករណ៍ជំនួយ ដូចជាឈើច្រត់
- ✓ ការជីកប្រឡាយ ឬអណ្តូង

ក្នុងចំណោមមនុស្ស ២៧ នាក់ ដែលបានស្នើសុំទៅរដ្ឋាភិបាល មាន ១៦ នាក់បានទទួលការឆ្លើយតបមកវិញ។ ចំណែក១១នាក់ទៀតមិនបានទទួលការឆ្លើយតបអ្វីនោះទេ។

## តើត្រូវការពេលយូរប៉ុន្មាន ដើម្បីទទួលបានការឆ្លើយតបពីរដ្ឋាភិបាល?

រយៈពេលនៃការឆ្លើយតបពីរដ្ឋាភិបាល អាស្រ័យទៅតាមប្រភេទនៃការស្នើសុំ និងកម្រិតសមត្ថកិច្ចរបស់រដ្ឋបាល។ ក្នុងករណីខ្លះ ដូចជាក្នុងករណីស្នើសុំឯកសារផ្លូវការរដ្ឋាភិបាល មានការកំណត់រយៈពេលជាក់លាក់មួយ ដើម្បីឆ្លើយតបមកពលរដ្ឋដែលបានធ្វើការស្នើសុំ។




អ្នកឆ្លើយសំណួរមួយចំនួនដែលបានស្នើសុំទៅរដ្ឋាភិបាលនិយាយថា សំណើរបស់គាត់បានទទួលការឆ្លើយតបផងដែរ។

អ្នកខ្លះនិយាយថា ពួកគាត់ទទួលបានការសន្យាថានឹងផ្តល់ជូន ប៉ុន្តែមិនទាន់ទទួលបានអ្វីនៅឡើយទេ។ អ្នកខ្លះទៀតនិយាយថា ពេលគាត់ទទួលដំណឹងពីសំណើរបស់គាត់មកវិញ គេប្រាប់ថា គេបានបញ្ជូនសំណើរបស់គាត់ទៅកម្រិតខ្ពស់មួយទៀតហើយ។

"ពួកគេនិយាយថា នឹងផ្តល់ឲ្យខ្ញុំ ប៉ុន្តែមកដល់ពេលនេះ ខ្ញុំមិនទាន់បានទទួលវានៅឡើយទេ។"

"ខ្ញុំទទួលបានអាហារ មីកញ្ចប់ និងឧបករណ៍ប្រើប្រាស់មួយចំនួន"
"ខ្ញុំបានស្នើសុំកញ្ចប់ថវិកាសម្រាប់មើលថែសុខភាពនៅពេលមានអាសន្ន ហើយពួកគេបានបញ្ជាក់ថានឹងបញ្ចុះថ្លៃសេវាព្យាបាលឲ្យខ្ញុំ"
"ពួកគេយល់ព្រមបរិច្ចាគរទេះរុញសម្រាប់ជនមានពិការភាព"

# ការសន្និដ្ឋាន

ការទទួលបានព័ត៌មានមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទាំងអស់។ ផលប៉ះពាល់ពីការមិនទទួលបានព័ត៌មាន គឺធ្វើឲ្យមនុស្សពុំបានទទួលសេវាកម្មផ្សេងៗ ឬនាំឲ្យពួកគាត់មិនអាចចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍នានាដែលគាត់មានសិទ្ធិទទួលបាន។

យើងព្យាយាមសិក្សាពីរបៀបរបបដែលជនមានពិការភាពទទួលបានព័ត៌មាន ថាតើអ្វីខ្លះដែលមានប្រសិទ្ធិភាព ឬគ្មានប្រសិទ្ធិភាពសម្រាប់គាត់។ ការសិក្សានេះបានបញ្ជាក់ថា ជនមានពិការភាពជាច្រើនមិនបានទទួលនូវព័ត៌មានដែលជាតម្រូវការរបស់ពួកគាត់នោះទេ ដោយសារតែពួកគាត់មិនបានទទួលដំណឹង គាត់មិនអាចរកព័ត៌មានទាំងនោះបាន ឬគាត់មិនអាចចូលទៅដល់ទីតាំងចែកចាយព័ត៌មានបាន។ វាមានគម្លាតខ្លាំងក្នុងការទទួលបានព័ត៌មានរវាងបុរស និងស្ត្រី ឬរវាងប្រភេទនៃពិការភាព។

តើអ្នកគិតយ៉ាងដូចម្តេច ? សូមចែករំលែកគំនិតរបស់អ្នកជាមួយនឹង Light for the World Cambodia។

ការសិក្សានេះជាផ្នែកមួយនៃគម្រោង ស្វែងរកមតិគាំទ្រ និងការប្រាស្រ័យទាក់ទងសម្រាប់ការផ្លាស់ប្តូរ (The Advocacy and Communication for Change program) ដោយអង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ (Disability Development Services Program) និងអង្គការ Light for the World។

ការស្រាវជ្រាវនេះចែកជាពីរដំណាក់កាលដែលដំណាក់កាលនីមួយៗធ្វើឡើងសម្រាប់ពាក់កណ្តាលខេត្តពោធិ៍សាត់។ ឯកសារនេះបង្ហាញពីលទ្ធផលនៃដំណាក់កាលទីពីរ ហើយលទ្ធផលនៃដំណាក់កាលទីមួយបានបោះពុម្ពផ្សាយក្នុងឯកសារដែលមានឈ្មោះថា "សារៈសំខាន់នៃព័ត៌មាន" កាលពីឆ្នាំ ២០១៨។



កម្មវិធី ការស្វែងរកមតិគាំទ្រ និងការប្រាស្រ័យទាក់ទង ដើម្បីការផ្លាស់ប្តូរ (The Advocacy and Communication for Change) ធ្វើការស្វែងយល់ពីជនមានពិការភាពដែលមានបទពិសោធន៍អំពីបញ្ហាប្រាស្រ័យទាក់ទង និងបញ្ហាទទួលបានព័ត៌មាន។

ឯកសារមួយនេះរៀបចំជារបៀបសាមញ្ញដើម្បីឲ្យគ្រប់គ្នាងាយយល់ពីលទ្ធផលនៃការសិក្សារបស់យើង។ បើលោកអ្នកចង់ស្វែងយល់ឲ្យស៊ីជម្រៅពីការសិក្សានេះ សូមទាក់ទងមក Light for the World។







យើងខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលមួយចំនួនដែលខិតខំធ្វើការងាររហូតទទួលបានការបោះពុម្ពមួយនេះ៖

លោក ផេង សំណាង (Mr. Pheng Samnang) លោក សំ សារ៉េត (Mr. Sam Sareth) ព្រមទាំងក្រុមការងារទាំងអស់ដែលបានធ្វើការប្រមូលទិន្នន័យពីអង្គការ Disability Development Service Program (DDSP)។ បុគ្គលិកមកពី Light for the World មានលោកស្រី ជូឌីត បាត (Mrs. Judith Bart) លោក ខេង វីរៈ (Mr. Kheng Virak) និងលោក ដេវីដ ខឺធីស (Mr. David Curtis)។ យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកតំណាងជនមានពិការភាពថ្នាក់ឃុំ និងថ្នាក់ភូមិ អាជ្ញាធរមូលដ្ឋាន និងប្រជាជននៅខេត្តពោធិ៍សាត់ ដែលបានចំណាយពេលវេលាផ្តល់ព័ត៌មានដល់ក្រុមការងាររបស់យើងខ្ញុំ។

ឡៃហ្វ័រឌឺវើលកម្ពុជា

d.curtis@light-for-the-world.org

Millennium Tower ( ជាន់ទីមួយ )
#៦៨ ផ្លូវ ៥៧ សង្កាត់បឹងកេងកង ១
ខណ្ឌចំការមន ភ្នំពេញ

DisabilityDevelopmentService
Program(DDSP)

ddsp@camintel.com
samnang65@yahoo.com
+៨៥៥ (0) ៥២ ៩៥១ ៤៩៥;
+៨៥៥ (0) ៩២ ២៦៦ ៤៩៣/ ១៧ ៨៧២ ១៩៩

ភូមិពាលញែក ២ សង្កាត់ផ្ទះព្រៃ
ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កម្ពុជា

អរគុណដល់ជំនួយគាំទ្រពី CEA

Civic Engagement Alliance
MEKONG

រចនាដោយ: ZOUT design & communication